គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៣៨ ចេញផ្សាយថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២
No. 38 Released on March 21, 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ការតែងតាំងបរធនបាល

# Appointment of Trustee



រូបភាព | Picture: maxresdefault.jpg (1280×720) (ytimg.com)

ដូចមានចែងក្នុងប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង រៀបចំ និងប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ដើម្បីទទួលបានការអនុញ្ញាតបង្កើត និងការចុះបញ្ជីបរធនបាលកិច្ច បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ត្រូវធ្វើការជ្រើសរើសបេក្ខភាពបរធនបាលដែលទទួលបានអាជ្ញាបណ្ណ និង/ ឬការអនុញ្ញាតពី **ន.ប.ធ.**។ បន្ទាប់ពីទទួលការអនុញ្ញាតជាស្ថាពរភ្លាមពីអគ្គនាយកនៃ **ន.ប.ធ.** បរធនបាល ដែលត្រូវបានអនុញ្ញាតតែងតាំង ត្រូវបន្តនីតិវិធីស្នើសុំបង្កើតបរធនបាលកិច្ចក្នុងនាមបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាតនោះ។

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច អាចតែងតាំងបរធនបាលមួយ ឬច្រើន សម្រាប់បរធនបាលកិច្ចមួយ ស្របតាមមាត្រា២០ នៃច្បាប់ស្តីពីបរធនបាលកិច្ច។ ការតែងតាំងបរធនបាលជារូបវន្តបុគ្គលច្រើនជាងមួយ បរធនបាលនោះត្រូវតែជាចំនួនសេស។ ប្រការនេះមិនអនុវត្តចំពោះបរធនបាលកិច្ច ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានោះទេ។

As stated in the Prakas on the Rule for the Management, Organization, and Functioning of the Trust, to obtain a permit for the establishment and registration of the trust, trustor or trust contributor must select the approved person who has obtained a license and/or permission from the **TR**. After immediately receiving the final permission from the Director General of the Trust Regulator, the appointed trustee must continue the procedures for applying for the establishment within 15 (fifteen) days after the date of the permit.

Trustor or Trust Contributor can appoint one or more trustees for a trust in line with Article 20 of the Law on Trust. The appointment of more than one Natural Person as the trustee must be an odd number. This Article does not apply to the trust created by the Royal Government of Cambodia.

**អត្ថបទ៖ បៀន ឃាងជូ | Article: Bean Kheangchou**

**ឯកសារយោង | References:**

- ប្រការ ៨ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)
- មាត្រា២០ នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.